N° 31
23-8-97

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៥ លេខ ៣១ ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ១៩៩៧

រាជកិច្ច

រួមមាន :

- ច្បាប់
- ព្រះរាជក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

LAM.

មាតិកា

I- ខុទ្ទកាល័យព្រះមហាក្សត្រ

១- ព្រះរាជក្រម

២២.៨.១៩៩៧ ព្រះរាជក្រម ជស/រកម/០៨៩៧/០៣ ច្បាប់ស្តីពីការគ្រប់គ្រងការប្តូរប្រាក់ ១៨៦៧

២- ព្រះរាជក្រឹត្យ

២៨.៧.១៩៩៧ ព្រះរាជក្រឹត្យ ជស/រកត/០៧៩៨/១១៣ តែងតាំងឯកឧត្តម ឈឹម ជួន
ជាទីប្រឹក្សាផ្ទាល់ សម្តេច ជា ស៊ីម ១៨៧៤

២៨.៧.១៩៩៧ ព្រះរាជក្រឹត្យ ជស/រកត/០៧៩៨/១១៤ តែងតាំងឯកឧត្តម គ្រីយ៍ បេងហុង
ជាទីប្រឹក្សាផ្ទាល់ សម្តេច ជា ស៊ីម ១៨៧៥

២៨.៧.១៩៩៧ ព្រះរាជក្រឹត្យ ជស/រកត/០៧៩៨/១១៥ តែងតាំងឯកឧត្តម ផង់ សារ៉េត
ជាទីប្រឹក្សាផ្ទាល់ សម្តេច ជា ស៊ីម ១៨៧៦

២៨.៧.១៩៩៧ ព្រះរាជក្រឹត្យ ជស/រកត/០៧៩៨/១១៦ តែងតាំងឯកឧត្តម លី ប៊ុនម៉េង
ជាទីប្រឹក្សាផ្ទាល់ សម្តេច ជា ស៊ីម ១៨៧៧

២៨.៧.១៩៩៧ ព្រះរាជក្រឹត្យ ជស/រកត/០៧៩៨/១១៧ តែងតាំងឯកឧត្តម ចុង បូរ៉េត
ជាទីប្រឹក្សាផ្ទាល់ សម្តេច ជា ស៊ីម ១៨៧៧

២៨.៧.១៩៩៧ ព្រះរាជក្រឹត្យ ជស/រកត/០៧៩៨/១១៨ តែងតាំងឯកឧត្តម យី យោន
ជាទីប្រឹក្សាផ្ទាល់ សម្តេច ជា ស៊ីម ១៨៧៨

២៨.៧.១៩៩៧ ព្រះរាជក្រឹត្យ ជស/រកត/០៧៩៨/១១៩ តែងតាំងឯកឧត្តម សោម ច័ន្ទរ៉ែម
ជាទីប្រឹក្សាផ្ទាល់ សម្តេច ជា ស៊ីម ១៨៧៩

២៨.៧.១៩៩៧ ព្រះរាជក្រឹត្យ ជស/រកត/០៧៩៨/១២០ តែងតាំងឯកឧត្តម ចៅ សុផុន
ជាទីប្រឹក្សាផ្ទាល់ សម្តេច ជា ស៊ីម ១៨៨០

២៨.៧.១៩៩៧ ព្រះរាជក្រឹត្យ ជស/រកត/០៧៩៨/១២១ តែងតាំងឯកឧត្តម ជា សុន
ជាទីប្រឹក្សាផ្ទាល់ សម្តេច ជា ស៊ីម ១៨៨០

២៨.៧.១៩៩៧ ព្រះរាជក្រឹត្យ ជស/រកត/០៧៩៨/១២២ តែងតាំងឯកឧត្តម ឧត្តមសេនីយ ទោ ឯល រ៉ាន់សាវ៉ាត ជាទីប្រឹក្សាផ្ទាល់ សម្តេច ជា ស៊ីម ១៨៨

២៨.៧.១៩៩៧ ព្រះរាជក្រឹត្យ ជស/រកត/០៧៩៨/១២៣ តែងតាំងឯកឧត្តម សោម សុផា ជាទីប្រឹក្សាផ្ទាល់ សម្តេច ជា ស៊ីម ១៨៨

២៨.៧.១៩៩៧ ព្រះរាជក្រឹត្យ ជស/រកត/០៧៩៨/១២៤ តែងតាំងឯកឧត្តម កុយ ប៊ុនថា ជាទីប្រឹក្សាផ្ទាល់ សម្តេច ជា ស៊ីម ១៨៨

២៨.៧.១៩៩៧ ព្រះរាជក្រឹត្យ ជស/រកត/០៧៩៨/១៦០ តែងតាំងឯកឧត្តម ឧត្តមសេនីយ ទោ ស៊ុយ កែវ ជាទីប្រឹក្សាផ្ទាល់ សម្តេច ជា ស៊ីម ១៨៨

II - រាជរដ្ឋាភិបាល

អនុក្រឹត្យ

១៨.៨.១៩៩៧ អនុក្រឹត្យលេខ ១៦២ អនក្រ ត.ត ស្តីពីការជូនមេដាយសហមេត្រី ១៨៨

III - ការិយាល័យក្រសួង

១- ទីស្តីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល

ប្រកាស

១៩.៨.១៩៩៧ ប្រកាសលេខ ៧៦៣ ឧក/ប្រក អនុញ្ញាតឱ្យក្រុមហ៊ុន យូ អេស អេ ហ្វុលលីហ្សៀល (កម្ពុជា) ហ្គាម៉ិន ខូអ៊ិលធីឌី តំណាងដោយលោក LING XIANG XIONG សញ្ជាតិចិន បង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់នាំចេញ ១៨៨

១៩.៨.១៩៩៧ ប្រកាសលេខ ៧៦៤ ឧក/ប្រក អនុញ្ញាតឱ្យលោក ទិវ ជីឃុន ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងជាងផលិតគ្រឿងដែក ១៨៩

១៩.៨.១៩៩៧ ប្រកាសលេខ ៧៦៥ ឧក/ប្រក អនុញ្ញាតឱ្យអ្នកស្រី សុខ ហៀង ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការ សិប្បកម្មកាត់កញ្ចក់ ១៨៩

១៩.៨.១៩៩៧ ប្រកាសលេខ ៧៦៦ ឧក/ប្រក អនុញ្ញាតឱ្យអ្នកស្រី អ៊ឹ ផាត់មុំ ជនជាតិ

	ខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការ សិប្បកម្មកាត់កញ្ចក់	១៨៨៧
១៩.៨.១៩៩៧	ប្រកាសលេខ ៧៦៧ ផក/ប្រក អនុញ្ញាតឱ្យលោក ម៉ាត់ លី ជនជាតិ ខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការ សិប្បកម្មកាត់កញ្ចក់	១៨៨៨
១៩.៨.១៩៩៧	ប្រកាសលេខ ៧៦៨ ផក/ប្រក អនុញ្ញាតឱ្យលោក ប៊ុន ឆាយ ជនជាតិ ខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការ សិប្បកម្មផលិត មីសរសៃ	១៨៨៨
១៩.៨.១៩៩៧	ប្រកាសលេខ ៧៦៩ ផក/ប្រក អនុញ្ញាតឱ្យលោក ប៊ុន នាម ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការ រោងជាងក្រឡឹងដែក និងចាក់គ្រឿង បន្ទាស់	១៨៨៩
១៩.៨.១៩៩៧	ប្រកាសលេខ ៧៧០ ផក/ប្រក អនុញ្ញាតឱ្យលោក ទី គក ជនជាតិខ្មែរ សញ្ជាតិ កម្ពុជា បន្តដំណើរការ រោងម៉ាស៊ីនកិនស្រូវកំលាំង៨០សេះ	១៨៨៩
១៩.៨.១៩៩៧	ប្រកាសលេខ ៧៧១ ផក/ប្រក អនុញ្ញាតឱ្យលោក ថៃ វ៉ាង ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការ រោងជាងផលិតខ្មៅប៊ិចឡុង	១៨៩០

២- ទីស្តីការរដ្ឋមន្ត្រី ក្រសួងពត៌មាន

ប្រកាស

១៩.៨.១៩៩៧	ប្រកាសលេខ ២២២/៩៧ ពម/ប្រក អនុញ្ញាតឱ្យទស្សនាវដ្តីប្រភេទ ពាណិជ្ជកម្មឈ្មោះ "សុខលាភ" របស់រោងពុម្ព "ជោគជ័យ" បោះពុម្ព ចែកផ្សាយ	១៨៩០
១៩.៨.១៩៩៧	ប្រកាសលេខ ២២៣/៩៧ ពម/ប្រក អនុញ្ញាតឱ្យបោះពុម្ពផ្សាយសារពត៌ មាន "ពាក្យ"	១៨៩២

៣- ទីស្តីការរដ្ឋមន្ត្រី ក្រសួងទេសចរណ៍

ប្រកាស

២១.៨.១៩៩៧	ប្រកាសលេខ ៨៥/ប្រក ស្តីពីការតែងតាំងមន្ត្រីរាជការ	១៨៩៣
២១.៨.១៩៩៧	ប្រកាសលេខ ៨៧/ប្រក ស្តីពីការតែងតាំងមន្ត្រីរាជការ	១៨៩៤

៤- ទីស្តីការ ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

ប្រកាស

២២.៨.១៩៩៧ ប្រកាសលេខ ១៤៥ បទ/ប្រក ស្តីពីការតែងតាំងបដិគ្គាហកៈ មន្ទីរប្រៃសណីយ៍ និង ទូរគមនាគមន៍ ខេត្តស្វាយរៀង ១៨៩[illegible]

៥- រដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ

សេចក្តីសំរេច

១៨.៨.១៩៩៧ សេចក្តីសំរេចលេខ ៤៦១ សសរ/មស/ក្រខ ស្តីពីការបែងចែកនិស្សិតចំនួន ២៧នាក់ ដែលទើបបញ្ចប់ការសិក្សាពីបរទេស ១៨៩[illegible]

៦- ទីស្តីការ ក្រសួងធម្មការ និង សាសនា

សេចក្តីសំរេច

២១.៨.១៩៩៧ សេចក្តីសំរេចលេខ ១៩១/៩៧ កធស អនុញ្ញាតឱ្យបើកសាខាស្នាក់ការបណ្តោះអាសន្ន សំរាប់ថ្វាយបង្គំព្រះត្រីស្តនិកាយប្រូតេស្តង់ នៃព្រះវិហារឈ្មោះ "ក្រុមជំនុំគ្រប់ជនជាតិទីក្រុងភ្នំពេញ" ស្ថិតនៅសង្កាត់ទឹកល្អក់ ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ១៩០

I - ខុទ្ទកាល័យព្រះមហាក្សត្រ

១. ព្រះរាជក្រម

ព្រះរាជក្រម ជស . រកម /០៨៩៧ . ០៣

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស
ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម
ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការ រៀបចំនិងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស./រកត/១០៩៤ /៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួល សមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ ជស./រកត/០៨៩៧ /១៤៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសំរួល សមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស./រកម/០១៩៦ /២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០៣ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំង ឯកឧត្តម ជា ចាន់តូ ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា
- បានឃើញច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីឯកឧត្តមនាយករដ្ឋមន្ត្រីទី១ សម្តេចនាយករដ្ឋមន្ត្រីទី២ និងអំពី អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការគ្រប់គ្រងការប្តូរប្រាក់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៧ នាសម័យប្រជុំលើកទី៨ នីតិកាលទី១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

ច្បាប់

ស្តីពី

ការគ្រប់គ្រងការប្តូរប្រាក់

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

ច្បាប់នេះអនុវត្តចំពោះរាល់ប្រតិបត្តិការរូបិយប័ណ្ណនិងជាទូទៅគឺ រាល់ប្រតិបត្តិការដែលប្រព្រឹត្ត ឡើងរវាងនិវាសជននិងអនិវាសជនទាក់ទងទៅនឹង :

- ការទូទាត់ពាណិជ្ជកម្ម
- ការផ្ទេរប្រាក់ ឬ
- ចលនានៃដើមទុន ដោយរាប់បញ្ចូលទាំងការវិនិយោគផង ។

មាត្រា ២.-

ត្រូវចាត់ទុកជារូបិយប័ណ្ណ សំរាប់ការអនុវត្តច្បាប់នេះ :

- មធ្យោបាយទូទាត់មូលប័ត្រ ជារូបិយវត្ថុបរទេស
- មាសមិនទាន់កែច្នៃឬលោហធាតុមានតម្លៃដទៃទៀតមិនទាន់កែច្នៃនិងត្បូងថ្មមានតម្លៃមិនទាន់កែច្នៃ ។

មាត្រា ៣.-

ត្រូវចាត់ទុកជានិវាសជន :

- រូបវ័ន្តបុគ្គលទាំងឡាយដោយពុំគិតពីសញ្ជាតិ ដែលមានសកម្មភាពចម្បងឬមានលំនៅឋានចំបងនៅក្នុងព្រះរាជាណាចក្រកម្ពុជាចាប់ពីមួយរយប៉ែតសិបពីថ្ងៃ (១៨២ថ្ងៃ) ឡើងទៅ វៀរលែងតែមន្ត្រីបរទេស ដែលបំពេញបេសកកម្មការទូតឬ បេសកជនប្រហាក់ប្រហែល

-នីតិបុគ្គលនៃច្បាប់ក្នុងប្រទេសនិងសាខានៅក្នុងព្រះរាជាណាចក្រកម្ពុជារបស់នីតិបុគ្គលនៃច្បាប់ក្រៅប្រទេស

- គ្រប់មន្ត្រីរាជការខ្មែរបំពេញភារកិច្ចនៅបរទេស ដោយឥតគិតពីរយៈពេលនៃការ ស្នាក់នៅ។

មាត្រា ៤.-

ត្រូវចាត់ទុកជាអនិវេសជន :

-រូបវន្តបុគ្គលសញ្ជាតិខ្មែរដែលមានសកម្មភាពចំបង ឬលំនៅឋានចំបង នៅបរទេស ចាប់ពីមួយរយប៉ែតសិបពីរថ្ងៃ (១៨២ថ្ងៃ) ឡើងទៅ

- រូបវន្តបុគ្គលបរទេសដែលមានសកម្មភាពចំបងឬលំនៅឋានចំបងនៅ ព្រះរាជាណាចក្រកម្ពុជា តិចជាងមួយរយប៉ែតសិបពីរថ្ងៃ (១៨២ថ្ងៃ)

- នីតិបុគ្គលនៃច្បាប់ក្នុងប្រទេសដែលមានទីតាំងនៅបរទេសនិងសាខានៅបរទេស របស់នីតិបុគ្គលនៃច្បាប់ក្នុងប្រទេស

- មន្ត្រីបរទេសដែលបំពេញបេសកកម្មការទូតនៅព្រះរាជាណាចក្រកម្ពុជាឬ បេសកជនប្រហាក់ប្រហែល ។

ជំពូកទី២

អន្តរការិយកម្មធនាគារ

មាត្រា ៥.-

១-រាល់ប្រតិបត្តិការប្តូរប្រាក់តាមរបៀបលេខនា ដោយមានរាប់បញ្ចូលការទិញនិងការលក់រូបិយប័ណ្ណលើផ្សារប្តូរប្រាក់ផង ការផ្ទេរប្រាក់ ការទូទាត់ក្រៅប្រទេស គ្រប់ប្រភេទក៏ដូចជា ចលនា ដើមទុនជារូបិយប័ណ្ណ ឬជារូបិយវត្ថុជាតិរវាងកម្ពុជានិងប្រទេសក្រៅ ឬ រវាងនិវេសជននិងអនិវេសជន អាចប្រព្រឹត្តទៅដោយសេរី ប៉ុន្តែប្រតិបត្តិការទាំងនោះ ត្រូវតែអនុវត្តដោយឆ្លងតាមអន្តរការីប្រតិស្រុតិ ។

២- មានតែធនាគារដែលមានទីតាំងជាប្រចាំនៅព្រះរាជាណាចក្រកម្ពុជាប៉ុណ្ណោះទេ ដែលត្រូវបានចាត់ទុកជាអន្តរការីប្រតិស្រុតិ ។

៣- អន្តរការីប្រតិស្រុតិ ក្រោមល័ក្ខខ័ណ្ឌដែលមានកំណត់ក្នុងបទបញ្ជា ត្រូវបង្ខំឱ្យផ្តល់ជូនធនាគារកណ្តាលជាទៀងទាត់ នូវរបាយការណ៍តាមកាលកំណត់ តាមប្រភេទនៃប្រតិបត្តិ ការផ្ទេរប្រាក់ ឬទូទាត់ និង ចលនានៃដើមទុនចេញ និងចូលដែលបានអនុវត្តរវាងព្រះរាជាណាចក្រកម្ពុជា និងប្រទេសក្រៅទៅតាមរយៈពេល ដែលនឹងកំណត់ដោយធនាគារកណ្តាល ។

៤-អន្តរការីប្រតិស្រុតិ ដែលធ្វើការនាំចេញសាច់ប្រាក់ជារូបិយប័ណ្ណ ត្រូវធ្វើប្រតិវេទន៍ជាមុនជូនធនាគាកណ្តាល ។

៥- អាជីវករប្តូរប្រាក់ដល់ដៃដែលមានទីតាំងអចល័តឬចល័តអាចធ្វើសកម្មភាពប្តូរប្រាក់បាន លុះត្រាតែបានទទួលការអនុញ្ញាតជាមុនពីធនាគារកណ្តាល ។

មាត្រា ៦.-

ក្នុងករណីមានវិបត្តិពីការប្តូរប្រាក់ ធនាគារកណ្តាលអាចចេញបទបញ្ជា... រយៈពេលយ៉ាងយូរ៣ខែ ដើម្បីកំណត់ល័ក្ខខ័ណ្ឌបណ្តោះអាសន្នខ្លះចំពោះសកម្មភាពរបស់អន្តរការីប្រតិស្រុតិ ជាអាទិ៍ ចំពោះប្រតិបត្តិការដែលមានចែងក្នុងមាត្រា៥ នៃច្បាប់នេះ ឬស្ថានភាពរូបិយប័ណ្ណរបស់ខ្លួន ឬការឱ្យខ្ចីជារូបិយវត្ថុជាតិទៅអនិវាសជន ។ ក្នុងករណីយត្រូវបន្តទៀតនោះ ធនាគារ...ណ្តាលត្រូវសហការ ជាមួយ ក្រសួង សេដ្ឋកិច្ចនិង ហិរញ្ញវត្ថុលើកសំណើសុំការ...មពីប្រមុខរាជរដ្ឋាភិបាល ។

មាត្រា ៧.-

និវាសជនអាចកាន់រ...រូបិយប័ណ្ណដោយសេរីទាំងទំរង់ ទាំងទីកន្លែងនៅក្នុងប្រទេស ។ ក្នុងករណីមានវិបត្តិពីការប្តូរប្រាក់ ធនាគារកណ្តាលអាចចេញបទបញ្ជា...រយៈពេលយ៉ាងយូរ ៣ខែដើម្បីផ្អាក់មិនឱ្យអនុវត្តបទប្បញ្ញត្តិនេះជាបណ្តោះអាសន្ន ។ ក្នុងករណីត្រូវបន្តទៀតនោះធនាគារកណ្តាល សហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញ...កសំណើសុំការយល់ព្រមពីប្រមុខរាជរដ្ឋាភិបាល ។

ជំពូកទី ៣

ប្រតិបត្តិការចរន្ត

មាត្រ...

អ្នកនាំចេញឬអ្នកនាំចូលទំនិញឬសេវា ត្រូវធ្វើការទូទាត់តាមរយៈអន្តរការីប្រតិស្រុតិនូវប្រតិ...ជួកម្មរបស់ខ្លួនជាមួយប្រទេសក្រៅ ។

មាត្រ...

...គារកណ្តាលអាចទាមទារឱ្យអន្តរការីប្រតិស្រុតិបង្ហាញនូវសក្ខីប័ត្រធនាគារវិកប្ប នៅពេលដែលជ... សុំទិញរូបិយប័ណ្ណដើម្បីទូទាត់ការនាំចូល និងនៅពេលក្រោយមកទៀតនូវសក្ខីប័ត្ររដ្ឋបាល ផ្សេងៗ ...បញ្ជាក់ថា ទំនិញបាននាំចូលមកក្នុងប្រទេសរួចហើយ ។

មាត្រា ១០.-

ចាប់តាំងពីពេលធ្វើប្រតិវេទន៍ ប្រាក់ចំណូលដែលបានមកពីការនាំចេញទំនិញឬសេវា ត្រូវបញ្ចូលក្នុងខ្ទង់ឥណទាននៃគណនីរបស់អ្នកនាំចេញ ដែលមានបើកនៅធនាគារវិកប្បស្របតាមមាត្រា ៥ នៃច្បាប់នេះ ។

មាត្រា ១១.-

មូលនិធិបដិភាគជារូបិយវត្ថុជាតិ ដែលបានមកពីការធ្វើពាណិជ្ជកម្មក្នុងប្រទេសនូវទំនិញនាំចូលក្នុងក្របខ័ណ្ឌការខ្ចីប្រាក់ពីក្រៅឬជាអំណោយ ត្រូវបង់ចូលខ្ទង់ឥណទាននៃគណនីរបស់រតនាគារជាតិ ដែលបើកនៅធនាគារកណ្តាលទៅតាមបែបបទដែលនឹងត្រូវកំណត់តាមកិច្ចព្រមព្រៀងរួមរវាងរតនាគារជាតិនិងធនាគារកណ្តាល ។

មាត្រា ១២.-

រាល់ការនាំចេញឬការចូលមាសមិនទាន់កែច្នៃ ត្បូងថ្មមានតម្លៃមិនទាន់កែច្នៃឬលោហធាតុមានតម្លៃមិនទាន់កែច្នៃដទៃទៀត អាចដំណើរការដោយសេរី ស្របតាមចំណុច ១ មាត្រា ៥ នៃច្បាប់នេះ ប៉ុន្តែត្រូវធ្វើប្រតិវេទន៍ជាមុននៅធនាគារកណ្តាល បើចំនួនទំនិញនៃប្រតិបត្តិការនីមួយៗមានតម្លៃស្មើ ឬលើសពីមួយម៉ឺន (១០.០០០) ដុល្លារអាមេរិក ។

មាត្រា ១៣.-

ការនាំចេញឬការនាំចូលដោយអ្នកដំណើរនូវមធ្យោបាយទូទាត់ជារូបិយប័ណ្ណដែលមានទឹកប្រាក់ស្មើឬលើសពីមួយម៉ឺន (១០.០០០) ដុល្លារអាមេរិក ឬជារូបិយវត្ថុជាតិដែលមានតម្លៃសមមូលនិងមួយម៉ឺន (១០.០០០) ដុល្លារអាមេរិកឬច្រើនជាងនេះ ត្រូវតែធ្វើប្រតិវេទន៍ចំពោះមន្ត្រីគយនៅពេលឆ្លងកាត់ច្រកព្រំដែននៃព្រះរាជាណាចក្រកម្ពុជា ។

តាមចំប្រាក់ចាប់តាំងពីកំរិតមួយដែលកំណត់ដោយបទបញ្ជារបស់ធនាគារកណ្តាល អ្នកនាំចេញត្រូវដាក់ជូនធនាគារកណ្តាលពិនិត្យជាមុន មុននឹងធ្វើការនាំចេញ ។

ជារៀងរាល់ខែ ទីចាត់ការគយនិងរដ្ឋាករត្រូវបញ្ជូនបញ្ជីនៃប្រតិវេទន៍ដូចបានកំណត់ខាងលើទៅធនាគារកណ្តាល ។

ជំពូកទី ៤

ការវិនិយោគ ចលនានៃដើមទុន

មាត្រា ១៤.-

ចលនានៃដើមទុនទាក់ទងនិងការវិនិយោគបរទេសនៅព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តតាមច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ១៥.-

ក្នុងករណីដែលការជំរះបញ្ជីនៃការវិនិយោគបរទេសបានប្រព្រឹត្តទៅស្របទៅតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ផលដែលបានមកពីការជំរះបញ្ជីនោះនឹងត្រូវផ្ទេរបានដោយសេរី ។

មាត្រា ១៦.-

ការធ្វើវិនិយោគនៃនិវេសនជននៅបរទេស ត្រូវធ្វើប្រតិវេទន៍ជាមុនដល់ធនាគារកណ្តាល ចំពោះទឹកប្រាក់មានចំនួនស្មើឬលើសពីមួយសែន (១០០.០០០) ដុល្លារអាមេរិក ។

មាត្រា ១៧.-

ការផ្ទេរប្រាក់ទាក់ទងនឹងការធ្វើវិនិយោគឬការជំរះបញ្ជីនៃការធ្វើវិនិយោគ ត្រូវធ្វើតាមរយៈអន្តរការីប្រតិស្រុតិដូចមានចែងក្នុងមាត្រា ៥ នៃច្បាប់នេះ ។ អន្តរការីប្រតិស្រុតិ ត្រូវធ្វើរបាយការណ៍ទៅធនាគារកណ្តាលជាក្រោយលើទឹកប្រាក់ធ្វើប្រតិបត្តិការម្តង១មានចំនួនស្មើ ឬលើសពីមួយសែន (១០០.០០០) ដុល្លារអាមេរិក ។

ជំពូកទី ៥

ចលនានៃដើមទុនផ្សេងៗ

មាត្រា ១៨.-

ការឱ្យប្រាក់គេខ្ចីនិងការខ្ចីប្រាក់ពីគេ ដោយរាប់បញ្ចូលទាំងឥណទានពាណិជ្ជកម្មផងរវាងនិវេសនជន និងអនិវេសនជនអាចប្រព្រឹត្តទៅដោយសេរី ឱ្យតែការខ្ចីនិងការសងវិញ ធ្វើតាមរយៈអន្តរការីប្រតិស្រុតិ ។

មាត្រា ១៩.-

ចលនានៃដើមទុនដែលជាលទ្ធផលនៃប្រតិបត្តិការទាំងនោះ (ការទូទាត់ថ្លៃទំនិញឬសេវានាំចូល និងនាំចេញ ការផ្ទេរប្រាក់ ការវិនិយោគ ការឱ្យប្រាក់គេខ្ចីនិងការខ្ចីប្រាក់ពីគេ) ត្រូវបញ្ចូលក្នុងរបាយការណ៍

ធនាគារជាប្រចាំ តាមការកំណត់ដែលមានចែងក្នុងចំណុច ៣ មាត្រា ៥ នៃច្បាប់នេះ ។ ចំលងនានៃដើមទុនទាំងនោះត្រូវកត់ត្រាតាមប្រភេទប្រតិបត្តិការនីមួយៗ ហើយត្រូវគោរពដល់ការសម្ងាត់វិជ្ជាជីវៈ ។

ជំពូកទី ៦

ទោសប្បញ្ញត្តិ

មាត្រា ២០.-

អន្តរការីប្រតិស្រុតិមានភារៈ ក្រោមការទទួលខុសត្រូវរបស់ខ្លួន ដោយប្រុងប្រយ័ត្ននូវការគោរពបប្បញ្ញត្តិទាំងឡាយដែលមានចែងក្នុងច្បាប់នេះ ឬដែលមានចែងក្នុងបទបញ្ជាទាំងឡាយនៃធនាគារកណ្តាល ដើម្បីអនុវត្តប្រតិបត្តិការដែលខ្លួនបានធ្វើដោយផ្ទាល់ឬដែលស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ខ្លួន ។

អន្តរការីប្រតិស្រុតិណាដែលមិនគោរពតាមបទប្បញ្ញត្តិនៃវាក្យខ័ណ្ឌខាងលើ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

មាត្រា ២១.-

ជនណាប្រព្រឹត្តល្មើសនឹងចំណុច ៣ ឬចំណុច ៤ ឬចំណុច ៥ នៃមាត្រា៥ ឬប្រព្រឹត្តល្មើសនឹងមាត្រា១៧ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយឆ្នាំ ដល់ប្រាំឆ្នាំ និងពិន័យជាប្រាក់ពីមួយលានរៀល (១.០០០.០០០ រៀល) ដល់ ដប់លានរៀល (១០.០០០.០០០រៀល) ឬផ្តន្ទាទោសណាមួយក្នុងទោសទាំងពីរនេះ ។

មាត្រា ២២.-

ជនណាប្រព្រឹត្តល្មើសនឹងមាត្រា១១ ឬ វាក្យខ័ណ្ឌទី១ នៃមាត្រា១៣ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ស្មើនឹងដប់ភាគរយ (១០ភាគរយ) នៃទឹកប្រាក់ល្មើស ។

មាត្រា ២៣.-

ជនណាប្រព្រឹត្តល្មើសនឹងមាត្រា១២ ឬមាត្រា ១៦ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ស្មើនឹងម្ភៃភាគរយ (២០ភាគរយ) នៃទឹកប្រាក់ល្មើស ។

មាត្រា ២៤.-

ជនណាប្រព្រឹត្តល្មើសនឹងវាក្យខ័ណ្ឌទី ២ នៃមាត្រា ១៣ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលានរៀល (១.០០០.០០រៀល) ដល់ដប់លានរៀល (១០.០០០.០០០ រៀល) ។ រីឯវត្ថុតាងត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋ ។

មាត្រា ២៥.- ... ដែលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិ មាត្រា ... ឬមាត្រា ១៨ នៃច្បាប់ ...

ត្រូវផ្តន្ទាទោសពិន័យ ជាប្រាក់ស្មើនឹងហាសិបភាគរយ (៥០ភាគរយ) នៃទឹកប្រាក់លើស ។

ជំពូកទី ៧

អវសានប្បញ្ញត្តិ

មាត្រា ២៦.- បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែសីហា ឆ្នាំ ១៩៩...

ក្នុងព្រះបរមនាម និង តាមព្រះរាជបញ្ជាសបង្គាប់

ប្រមុខរដ្ឋស្តីទី

ជា ស៊ីម

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

បានជម្រាបជូន

ឯកឧត្តមនាយករដ្ឋមន្ត្រីទី១និងសម្តេចនាយករដ្ឋមន្ត្រីទី២ នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា ហត្ថលេខា

ហត្ថលេខា **អ៊ឹង ហួត** **ហ៊ុន សែន**

ថោ ប៉េងលាត

★★★

ក្រឹត្យ

ក្រឹត្យ ចស/រកត/០៧៩៧/១១៣

ប្រមុខរដ្ឋស្តីទីនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភាព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

- យោងតាមសំណូមពរចាំបាច់នៃការងារ

បង្គាប់

មាត្រា ១.-

តែងតាំងឯកឧត្តម **ឈិច ថុំន** ជាទីប្រឹក្សាផ្ទាល់របស់សម្តេច **ជា ស៊ីម** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២.-

អគ្គលេខាធិការដ្ឋានរដ្ឋសភា ខុទ្ទកាល័យផ្ទាល់ប្រធានរដ្ឋសភា និងសាមីជនត្រូវប្រតិបត្តិឱ្យបានសំរេចតាមក្រឹត្យនេះ ។

មាត្រា ៣.-

ក្រឹត្យនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ថ្ងៃ ទី ២៨ ខែកក្កដា ឆ្នាំ ១៩៩៧

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

★★★

ក្រឹត្យ ចស . រកត . ០៧៩៧/១១៤

ប្រមុខរដ្ឋស្តីទីនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣
- បានឃើញបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភាព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- យោងតាមសំណូមពរចាំបាច់នៃការងារ

បង្គាប់

មាត្រា ១.-

តែងតាំងឯកឧត្តម **ត្រឹយ សេងហុង** ជាទីប្រឹក្សាផ្ទាល់របស់សម្តេច **ជា ស៊ីម** ប្រធានរដ្ឋសភានៃ ព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២.-

អគ្គលេខាធិការដ្ឋានរដ្ឋសភា ខុទ្ទកាល័យផ្ទាល់ប្រធានរដ្ឋសភា និងសាមីជនត្រូវប្រតិបត្តិឱ្យបានសម្រេចតាមក្រឹត្យនេះ ។

មាត្រា ៣.-

ក្រឹត្យនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃ ចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ,ថ្ងៃ ទី ២៨ ខែកក្កដា ឆ្នាំ ១៩៩៧

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

★★★

ក្រឹត្យ ជស . រកត . ០៧៩៧/១១៥ .

ប្រមុខរដ្ឋស្តីទីនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣
- បានឃើញបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភាព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- យោងតាមសំណូមពរចាំបាច់នៃការងារ

សម្រេច

មាត្រា ១.- តែងតាំងឯកឧត្តម ផង់ សារ៉េត ជាទីប្រឹក្សាផ្ទាល់របស់សម្តេច ជា ស៊ីម ប្រធាន រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២.- អគ្គលេខាធិការដ្ឋានរដ្ឋសភា ខុទ្ទកាល័យផ្ទាល់ប្រធានរដ្ឋសភា និងសាមីជនត្រូវប្រតិបត្តិឱ្យបានសម្រេចតាមក្រឹត្យនេះ ។

មាត្រា ៣.- ក្រឹត្យនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃ ចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ,ថ្ងៃ ទី ២៨ ខែកក្កដា ឆ្នាំ ១៩៩៧

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

ក្រឹត្យ ជស . រកត . ០៧៩៧/១១៦

ប្រមុខរដ្ឋស្តីទីនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣
- បានឃើញបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភាព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- យោងតាមសំណូមពរចាំបាច់នៃការងារ

សម្រេច

មាត្រា ១.-

តែងតាំងឯកឧត្តម **ឈី ប៊ុនចេង** ជាទីប្រឹក្សាផ្ទាល់របស់សម្តេច **ជា ស៊ីម** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២.-

អគ្គលេខាធិការដ្ឋានរដ្ឋសភា ខុទ្ទកាល័យផ្ទាល់ប្រធានរដ្ឋសភា និងសាមីជនត្រូវប្រតិបត្តិឱ្យបានសំរេចតាមក្រឹត្យនេះ ។

មាត្រា ៣.-

ក្រឹត្យនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃ ចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ,ថ្ងៃ ទី ២៨ ខែកក្កដា ឆ្នាំ ១៩៩៧

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

★★★

ក្រឹត្យ ជស . រកត . ០៧៩៧/១១៧

ប្រមុខរដ្ឋស្តីទីនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣
- បានឃើញបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភាព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- យោងតាមសំណូមពរចាំបាច់នៃការងារ

សម្រេច

មាត្រា ១.-

តែងតាំងឯកឧត្តម ចុង ប៊ូរ៉េត ជាទីប្រឹក្សាផ្ទាល់របស់សម្តេច ជា ស៊ីម ប្រធានរដ្ឋសភាព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២.-

អគ្គលេខាធិការដ្ឋានរដ្ឋសភា ខុទ្ទកាល័យផ្ទាល់ប្រធានរដ្ឋសភា និងសាមីជនត្រូវប្រតិបត្តិឱ្យមានសំរេចតាមក្រឹត្យនេះ ។

មាត្រា ៣.-

ក្រឹត្យនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃ ចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ថ្ងៃ ទី ២៨ ខែកក្កដា ឆ្នាំ ១៩៩៧

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

★★★

ក្រឹត្យ ជស . រកត . ០៧៩៧/១១៨

ប្រមុខរដ្ឋស្តីទីនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣
- បានឃើញបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភាព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- យោងតាមសំណូមពរចាំបាច់នៃការងារ

សម្រេច

មាត្រា ១.-

តែងតាំងឯកឧត្តម ឃើ យោន ជាទីប្រឹក្សាផ្ទាល់របស់សម្តេច ជា ស៊ីម ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២.-

អគ្គលេខាធិការដ្ឋានរដ្ឋសភា ខុទ្ទកាល័យផ្ទាល់ប្រធានរដ្ឋសភា និងសាមីជនត្រូវប្រតិបត្តិឱ្យមានសំរេចតាមក្រឹត្យនេះ ។

មាត្រា ៣.-

ក្រឹត្យនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃ ចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ,ថ្ងៃ ទី ២៨ ខែកក្កដា ឆ្នាំ ១៩៩៧

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

★★★

ក្រឹត្យ ៩ស , រកត , ០៧៩៧/១១៩

ប្រមុខរដ្ឋស្តីទីនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣
- បានឃើញបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភាព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- យោងតាមសំណូមពរចាំបាច់នៃការងារ

បង្គាប់

មាត្រា ១.-

តែងតាំងឯកឧត្តម **សោម ចំន្ទរឹម** ជាទីប្រឹក្សាផ្ទាល់របស់សម្តេច **ជា ស៊ីម** ប្រធានរដ្ឋសភានៃ ព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២.-

អគ្គលេខាធិការដ្ឋានរដ្ឋសភា ខុទ្ទកាល័យផ្ទាល់ប្រធានរដ្ឋសភា និងសាមីជនត្រូវប្រតិបត្តិឱ្យបានសំរេចតាមក្រឹត្យនេះ ។

មាត្រា ៣.- ក្រឹត្យនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃ ចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ,ថ្ងៃ ទី ២៨ ខែកក្កដា ឆ្នាំ ១៩៩៧

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

★★★

ក្រឹត្យ ជស , រកត , ០៧៩៧/១២០

ប្រមុខរដ្ឋស្តីទីនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣
- បានឃើញបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភាព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- យោងតាមសំណូមពរចាំបាច់នៃការងារ

បង្គាប់

មាត្រា ១.-

តែងតាំងឯកឧត្តម **ទៅ សុផុន** ជាទីប្រឹក្សាផ្ទាល់របស់សម្តេច **ជា ស៊ីម** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២.-

អគ្គលេខាធិការដ្ឋានរដ្ឋសភា ខុទ្ទកាល័យផ្ទាល់ប្រធានរដ្ឋសភា និងសាមីជនត្រូវប្រតិបត្តិឱ្យបានសំរេចតាមក្រឹត្យនេះ ។

មាត្រា ៣.-

ក្រឹត្យនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃ ចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ថ្ងៃ ទី ២៨ ខែកក្កដា ឆ្នាំ ១៩៩៧

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

★★★

ក្រឹត្យ ជស , រកត , ០៧៩៧/១២១

ប្រមុខរដ្ឋស្តីទីនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣
- បានឃើញបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភាព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- យោងតាមសំណូមពរចាំបាច់នៃការងារ

សម្រេច

មាត្រា ១.-

តែងតាំងឯកឧត្តម ជា សុន ជាទីប្រឹក្សាផ្ទាល់របស់សម្ដេច ជា ស៊ីម ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុ... នេះស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២.-

អគ្គលេខាធិការដ្ឋានរដ្ឋសភា ខុទ្ទកាល័យផ្ទាល់ប្រធានរដ្ឋសភា និងសាមីជនត្រូវប្រតិបត្តិឱ្យបានសំរេចតាមក្រឹត្យនេះ ។

មាត្រា ៣.-

ក្រឹត្យនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃ ចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ,ថ្ងៃ ទី ២៨ ខែកក្កដា ឆ្នាំ ១៩៩៧

ប្រមុខរដ្ឋស្ដីទី

ហត្ថលេខា

ជា ស៊ីម

★★★

ក្រឹត្យ ជស , រកត , ០៧៩៧/១២២

ប្រមុខរដ្ឋស្ដីទីនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣
- បានឃើញបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភាព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- យោងតាមសំណូមពរចាំបាច់នៃការងារ

សម្រេច

មាត្រា ១.-

តែងតាំងឯកឧត្តម ឯល វ៉ាន់សារ៉ាត់ ជាទីប្រឹក្សាផ្ទាល់របស់សម្ដេច ជា ស៊ីម ប្រធានរដ្ឋសភានៃ ព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២.-

អគ្គលេខាធិការដ្ឋានរដ្ឋសភា ខុទ្ទកាល័យផ្ទាល់ប្រធានរដ្ឋសភា និងសាមីជនត្រូវប្រតិបត្តិឱ្យបានសំរេចតាមក្រឹត្យនេះ ។

មាត្រា ៣.-

ក្រឹត្យនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃ ចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ,ថ្ងៃ ទី ២៨ ខែកក្កដា ឆ្នាំ ១៩៩៧

ប្រមុខរដ្ឋស្ដីទី

ហត្ថលេខា

ជា ស៊ីម

★★★

ក្រឹត្យ ជស . រកត . ០៧៩៧/១២៣

ប្រមុខរដ្ឋស្ដីទីនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣
- បានឃើញបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភាព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- យោងតាមសំណូមពរចាំបាច់នៃការងារ

បង្គាប់

មាត្រា ១.-

តែងតាំងឯកឧត្ដម **សោម សុផា** ជាទីប្រឹក្សាផ្ទាល់របស់សម្ដេច **ជា ស៊ីម** ប្រធាន រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២.-

អគ្គលេខាធិការដ្ឋានរដ្ឋសភា ខុទ្ទកាល័យផ្ទាល់ប្រធានរដ្ឋសភា និងសាមីជនត្រូវប្រតិបត្តិឱ្យបានសំរេចតាមក្រឹត្យនេះ ។

មាត្រា ៣.- ក្រឹត្យនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃ ចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ,ថ្ងៃ ទី ២៨ ខែកក្កដា ឆ្នាំ ១៩៩៧

ប្រមុខរដ្ឋស្ដីទី

ហត្ថលេខា

ជា ស៊ីម

★★★

ក្រឹត្យ ជស . រកត . ០៧៩៧/១២៤

ប្រមុខរដ្ឋស្តីទីនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣
- បានឃើញបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភាព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- យោងតាមសំណូមពរចាំបាច់នៃការងារ

បង្គាប់

មាត្រា ១.-

តែងតាំងឯកឧត្តម **កុយ ប៊ុនថា** ជាទីប្រឹក្សាផ្ទាល់របស់សម្តេច **ជា ស៊ីម** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២.-

អគ្គលេខាធិការដ្ឋានរដ្ឋសភា ខុទ្ទកាល័យផ្ទាល់ប្រធានរដ្ឋសភា និងសាមីជនត្រូវប្រតិបត្តិឱ្យបានសម្រេចតាមក្រឹត្យនេះ ។

មាត្រា ៣.-

ក្រឹត្យនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃ ចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ថ្ងៃ ទី ២៨ ខែកក្កដា ឆ្នាំ ១៩៩៧

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

★★★

ព្រះរាជក្រឹត្យ ជស . រកត . ០៨៩៧/១៦០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាតិ វិសុទ្ធពង្ស

អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ខែវិច្ឆិកា ឆ្នាំ១៩៩៣ ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤
- យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៧

ត្រាស់បង្គាប់

មាត្រា ១.-

ត្រូវបានតែងតាំង និងតម្លើងឋានៈជូនឯកឧត្តម ឧត្តមសេនីយ៍ទោ ស៊ើយ កែម ជាទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី២ មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២.-

នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះឱ្យបានសំរេច ។

មាត្រា ៣.-

ព្រះរាជក្រឹត្យនេះចូលជាធរមានច្បាប់ចាប់ពីថ្ងៃ ឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃ ទី ២២ ខែសីហា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

***

II - រាជរដ្ឋាភិបាល

១. អនុក្រឹត្យ

អនុក្រឹត្យ លេខ ១៦២ អនក្រ.តត ស្តីពីការផ្ទេរមេដាយ សហមេត្រី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុព្រះមហាក្សត្រ

នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤

- បានឃើញព្រះរាជក្រឹត្យលេខ ជ.ស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

សម្រេច

មាត្រា ១.- ត្រូវបានប្រគល់មេដាយធិបឌិន្ទ សហមេត្រី ជូនឯកឧត្តម SHOHEI NAITO ឯកអគ្គរាជទូតនៃប្រទេសជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលបានខិតខំប្រឹងប្រែងឥតសំចៃក្នុងការពង្រឹងនិងពង្រីកទំនាក់ទំនង សហប្រតិបត្តិការទ្វេភាគីដ៏ល្អប្រសើរ លើគ្រប់វិស័យ រវាងជប៉ុននិងកម្ពុជា ព្រមទាំងជួយជំរុញយ៉ាងសកម្ម ឱ្យរដ្ឋាភិបាលជប៉ុន ផ្ដល់ជំនួយសេដ្ឋកិច្ចដ៏ច្រើនសន្ធឹកសន្ធាប់ដល់ព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២.- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែសីហា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

អ៊ឹង ហួត **ហ៊ុន សែន**

★★★

III - ការងារបណ្តាក្រសួង

១. ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល

ប្រកាស

ប្រកាសលេខ ៧៦៣ ឧក.ប្រក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៩៧

ប្រការ ១ : អនុញ្ញាតឱ្យក្រុមហ៊ុន យូ អេស អេ ហ៊្វុលលី ហ្វៀល (កម្ពុជា) ហ្គាម៉ិន ខូ អិលធីឌី (U.S.A FULLY FIELD (CAMBODIA) GARMENTS Co., LTD) តំណាងដោយលោក LING XIANG XIONG សញ្ជាតិចិន ភេទប្រុស អាយុ៣៧ឆ្នាំ អាស័យដ្ឋាន 17/F., TUNG NAM COMM . CENTRE,68,PORTLAND ST.,KOWLLOON, HONG KONG កាន់លិខិតឆ្លងដែនលេខ ភ២៨៣៣០៦៩ ចុះថ្ងៃទី ២១-៨-១៩៩៦ បង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់នាំចេញ ដែលមានឈ្មោះថា : " យូ អេស អេ ហ៊្វុល ហ្វៀល (កម្ពុជា) ហ្គាមីន " មានទីតាំងដីឡូត៍លេខ ៧៩០ ផ្លូវជាតិលេខ២ សង្កាត់ចាក់អង្រែក្រោម ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ ។

ប្រការ ២ : ការសាងសង់និងរៀបចំគ្រឿងចក្រ ត្រូវធ្វើទៅតាមប្លង់ដែលបានតំកល់ទុកនៅក្រសួង ឧស្សាហកម្មរ៉ែ និងថាមពល ឱ្យបានសំរេចក្នុងរយៈពេល០៦ខែ ដោយរាប់បញ្ចូលទាំងរយៈពេលដំណើរការសាកល្បងផង ។

ប្រការ ៣ : ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិស្ថាន និងគុណភាពផលិតផល ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ ជូនក្រសួងឧស្សាហកម្មរ៉ែ និងថាមពល អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ។

ប្រការ ៤ : រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យផលិតនូវ "សំលៀកបំពាក់" ទៅតាមគំរូដែលបានតំកល់ទុកនៅក្រសួងឧស្សាហម្មរ៉ែ និងថាមពល ។

ប្រការ ៥ : រាល់ការនាំចេញផលិតផលសំរេចត្រូវមានវិញ្ញាបនប័ត្របញ្ជាក់ផលិតកម្មពីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ។

ប្រការ ៦ : ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬល្មើសធូន់ធ្ងរនិងប្រការណាមួយដែលបានចែងខាងលើប្រកាសនេះនិងត្រូវដកហូតទុកវិញដោយគ្មានសំណងឡើយ ។

***

ប្រកាសលេខ ៧៦៤ ឧក.ប្រក ចុះថ្ងៃ ទី ១៩ ខែសីហា ឆ្នាំ ១៩៩៧

ការ៖ ១ : អនុញ្ញាតឱ្យលោក ទីវ ជីឃុន ជនជាតិខ្មែរ សញ្ជាតិកម្ពុជាកាន់អត្តសញ្ញាណប័ណ្ណ លេខ ២៥២៨២៦ ភ.ព ចុះ ថ្ងៃ ទី ១៩-៨-៩៣ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៣៥E0 ផ្លូវលេខ ៥៥ សង្កាត់ចតុមុខ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ បន្តដំណើរការរោងជាងផលិតគ្រឿងដែក យីហោ "CAMBOART" នៅក្នុងទីតាំងផ្ទះលេខ ១២៣ ផ្លូវជាតិលេខ២ សង្កាត់ចាក់អង្រែលើ ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ ។

ការ៖ ២ : ប្រកាសនេះមានតម្លៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់នេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កឱ្យមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

***

ប្រកាសលេខ ៧៦៥ ឧក.ប្រក ចុះថ្ងៃ ទី ១៩ ខែសីហា ឆ្នាំ ១៩៩៧

ការ៖ ១ : អនុញ្ញាតឱ្យអ្នកស្រី **សុខ ហៀង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជាកាន់អត្តសញ្ញាណ ប័ណ្ណ លេខ ១២៦២៩៦ ភ.ព ចុះ ថ្ងៃ ទី ២៥-៥-៩៥ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៥៣៨E0 ផ្លូវជាតិ លេខ ៥ ភូមិក្រោលគោ សង្កាត់គីឡូម៉ែត្រលេខ៦ ខ័ណ្ឌឬស្សីកែវ រាជធានីភ្នំពេញ បន្តដំណើរការសិប្បកម្មកាត់កញ្ចក់នៅក្នុងទីតាំង ផ្ទះលេខ ១៣E0 ផ្លូវលេខ២១៧ ភូមិទី២ សង្កាត់អូឬស្សីទី២ ខ័ណ្ឌ៧មករា រាជធានីភ្នំពេញ ។

ការ៖ ២ : ប្រកាសនេះមានតម្លៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់នេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កឱ្យមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

***

ប្រកាសលេខ ៧៦៦ ឧក.ប្រក ចុះថ្ងៃ ទី ១៩ ខែសីហា ឆ្នាំ ១៩៩៧

ការ៖ ១ : អនុញ្ញាតឱ្យអ្នកស្រី **អ៊ុំ សាត់ម៉ី** ជនជាតិខ្មែរ សញ្ជាតិកម្ពុជាកាន់អត្តសញ្ញាណ ប័ណ្ណលេខ ២២៤៥៩៥ ភ.ព ចុះ ថ្ងៃ ទី ២១-៧-៩០ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ១១ ផ្លូវលេខ១១៧

សង្កាត់បឹងកេងកង២ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ បន្តដំណើរការសិប្បកម្មកាត់កញ្ចាក់នៅក្នុ តាំង ផ្ទះលេខ ២៩ E0 ផ្លូវលេខ២១៧ ភូមិទី២ សង្កាត់អូរឬស្សីទី២ ខ័ណ្ឌ៧មករា រាជធ ភ្នំពេញ ។

ប្រការ ២ : ប្រកាសនេះមានតម្លៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់នេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំ អនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កឱ្យមាន ប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

★★★

ប្រកាសលេខ ៧៦៧ ឧក.ប្រក ចុះថ្ងៃ ទី ១៩ ខែសីហា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតឱ្យលោក **ម៉ាត់ លី** ជនជាតិខ្មែរ សញ្ជាតិកម្ពុជាកាន់អត្តសញ្ញាណ ប័ណ្ណ ៣២៤៧៦៦ ភ.ព ចុះ ថ្ងៃ ទី ២០-៤-៩២ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៤៩E0 ផ្លូវលេខ១ ក្រុមទី៦៨ សង្កាត់វាលវង់ ខ័ណ្ឌ៧មករា រាជធានីភ្នំពេញ បន្តដំណើរការសិប្បកម្ម កាត់កញ្ចក់ និ ផលិតទ្វារ-បង្អួចពីអាលុយមីញ៉ូម នៅក្នុងទីតាំង ផ្ទះលេខ២៩៩E0 ផ្លូវលេខ២១៧ ភូមិ សង្កាត់អូរឬស្សីទី២ ខ័ណ្ឌ៧មករា រាជធានីភ្នំពេញ ។

ប្រការ ២ : ប្រកាសនេះមានតម្លៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់នេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំ អនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កឱ្យមាន ប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

★★★

ប្រកាសលេខ ៧៦៨ ឧក.ប្រក ចុះថ្ងៃ ទី ១៩ ខែសីហា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតឱ្យលោក **ម៉ិន ឆាយ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជាកាន់អត្តសញ្ញាណប័ណ្ណ ២៩៩៤៧៧ ភ.ព ចុះ ថ្ងៃ ទី ០៨-១១-៩០ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៨២E0 ផ្លូវលេខ១ ភូមិទី២ សង្កាត់អូរឬស្សីទី២ ខ័ណ្ឌ៧មករា រាជធានីភ្នំពេញ បន្តដំណើរការសិប្បកម្មផលិ សរសៃ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតម្លៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់នេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំ អនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ផលិតផល

គុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្កឱ្យមានការ ប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះ នឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

***

ប្រកាសលេខ ៧៦៩ ផក.ប្រក ចុះថ្ងៃ ទី ១៩ ខែសីហា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតឱ្យលោក **ម៉ុន នាម** ជនជាតិខ្មែរ សញ្ជាតិកម្ពុជាកាន់អត្តសញ្ញាណ ប័ណ្ណលេខ ៣២០៥៧៧ ភ.៣ ចុះ ថ្ងៃ ទី ២៥-៩-៩១ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ៤៧៨ ផ្លូវលេខ៣៦៩ ភូមិដើមចាន់ សង្កាត់ផ្សារអំពៅទី២ ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ បន្តដំណើរការសិប្បកម្ម រោងជាងក្រឡឹង និងចាក់គ្រឿងបន្លាស់ នៅក្នុងទីតាំង ផ្ទះលេខ១០៣ ផ្លូវលេខ៣៦៩ ភូមិដើមចាន់ សង្កាត់ផ្សារអំពៅទី២ ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ ។

ប្រការ ២ : ប្រកាសនេះមានតម្លៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់នេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កឱ្យមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

***

ប្រកាសលេខ ៧៧០ ផក.ប្រក ចុះថ្ងៃ ទី ១៩ ខែសីហា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតឱ្យលោក **ឌី គក** ជនជាតិខ្មែរ សញ្ជាតិកម្ពុជាកាន់អត្តសញ្ញាណ ប័ណ្ណលេខ ១០០០២២ ភ.៣ ចុះ ថ្ងៃ ទី ១១-៤-៨៥ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ៤២៧ ផ្លូវលេខ៣៦៩ ភូមិព្រះពន្លា សង្កាត់ព្រែកប្រា ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ បន្តដំណើរការ រោងម៉ាស៊ីនកិនស្រូវកំលាំង ៨០សេះ នៅក្នុងទីតាំង ផ្ទះលេខ៥២ វិថីពោធិកំបោរ ភូមិឬស្សី សង្កាត់ស្ទឹងមានជ័យ ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ ។

ប្រការ ២ : លោក **ឌី គក** ត្រូវបន្តដំណើរផលិតកម្ម-អាជីវកម្មលើទីតាំងដូចបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ១ ឱ្យបានយ៉ាងតិចបំផុត ៦៥ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតម្លៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់នេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កឱ្យមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រកាសលេខ ៧៧១ ឧក.ប្រក ចុះថ្ងៃ ទី ១៩ ខែសីហា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតឱ្យលោក **ថៃ ទ័ាង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជាកាន់អត្តសញ្ញាណប័ណ្ណលេ
០៦១២៩៨ ភ.ព ចុះ ថ្ងៃ ទី ១៦-០២-៨៥ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ០១ ផ្លូវលេខ
សង្កាត់បឹងកេងកងទី១ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ បន្តដំណើរការ រោងជាងផលិតខ្ចៅប៊ូឡុ
និងដែកគោល យីហោ " សន្តិភាព " សញ្ញា " រូបព្រាបស " នៅក្នុងទីតាំង ផ្ទះលេខ១
ផ្លូវលេខ២៥៥ សង្កាត់បឹងសាឡាង ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ។

ប្រការ ២ : លោក **ថៃ ទ័ាង** ត្រូវបានអនុញ្ញាតឱ្យផលិតនូវមុខផលិតផល ខ្ចៅប៊ូឡុង និង ដែកគោ
យីហោ " សន្តិភាព " សញ្ញា " រូបព្រាបស " ស្របតាមគំរូសញ្ញាសំគាល់ ដែលបានតំកល់ទុក
ក្រសួង ឧស្សាហកម្មរ៉ែ និងថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតម្លៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់នេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំ
អនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កឱ្យមាន
ប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ពុ សុធីរៈ

***

២. **ទីស្តីការរដ្ឋមន្ត្រី ក្រសួងពត៌មាន**

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ១៩៩

ប្រកាសលេខ ២២២ , ៩៧ , ព.ម , ប្រក

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ជំពូក៣ មាត្រាទី៤១

- បានឃើញព្រះរាជក្រឹត្យព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ខែវិច្ឆិកា ឆ្នាំ១៩៩៣ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្តីពីរបបសារពត៌មាន នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះក្រមលេខ នស.រកម ០៨៩៥-០៧ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៥
- បានឃើញច្បាប់អនុញ្ញាតរបស់ក្រសួងពត៌មានលេខ ០៣៤.៩៦ ព.ម.ប្រក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការធ្វើអាជីវកម្មរោងពុម្ពដែលមានឈ្មោះ "ជោគជ័យ" របស់លោក ប៉ែន ផល្លា
- បានឃើញសំណើសុំបើកទស្សនាវដ្តីប្រភេទពាណិជ្ជកម្មឈ្មោះ "សុខលាភ" របស់លោក ប៉ែន ផល្លា ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៩៧

សំរេច

ប្រការ ១ : អនុញ្ញាតឱ្យទស្សនាវដ្តីប្រភេទពាណិជ្ជកម្មឈ្មោះ "**សុខលាភ**" របស់រោងពុម្ព "**ជោគជ័យ**" បោះពុម្ពចែកផ្សាយដោយមានលោក **ប៉ែន ផល្លា** ជាចាងហ្វាងការផ្សាយ ។ ទីស្នាក់ការផ្ទះលេខ៧៤៩ ផ្លូវមុនីវង្ស ក្រុមទី១០ សង្កាត់បឹងត្របែក ក្រុងភ្នំពេញ ។ ក្នុងករណីមានការផ្លាស់ប្តូរចំណុចណាមួយក្នុងអត្តសញ្ញាណនៃសារពត៌មានរបស់ខ្លួន ត្រូវជូនដំណឹងជាមុន ០៥ថ្ងៃ មកក្រសួងពត៌មានដើម្បីរងចាំសេចក្តីសំរេចជាថ្មី ។

ប្រការ ២ : រាល់ដំណើរការបោះពុម្ពចែកផ្សាយត្រូវគោរពតាមគោលការណ៍ ក្រមសីលធម៌អ្នកកាសែត ច្បាប់ស្តីពីរបបសារពត៌មាននិងច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ ត្រូវប្រគល់កាសែតចំនួន០៦ច្បាប់រៀងរាល់លេខចេញផ្សាយមកតំកល់ទុកជាឯកសារនៅក្រសួងពត៌មាន ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តល្មើស នឹងសេចក្តីដូចមានចែងក្នុងប្រការទាំងឡាយខាងលើ សាម៉ីខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៤ : អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានមណ្ឌលពត៌មាន នៃក្រសួងពត៌មាន និងចាងហ្វាងកាសែត "សុខលាភ" ត្រូវអនុវត្តនូវប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះមានប្រសិទ្ធភាពរយៈពេល០៣ឆ្នាំ និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ
ហត្ថលេខា និង ត្រា
ខៀវ កាញារីទ្ធ

***

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ១៩៩៧

ប្រកាសលេខ ២២៣ . ៩៧ . ព.ម . ប្រក

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ជំពូក៣ មាត្រាទី៤១
- បានឃើញព្រះរាជក្រឹត្យព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ខែវិច្ឆិកា ឆ្នាំ១៩៩៣ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្តីពីរបបសារព័ត៌មាន នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះក្រមលេខ នស.រកម ០៨៩៥-០៧ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៥
- បានឃើញសំណើសុំបើកសារពត៌មានឈ្មោះ "ធាត្មី" ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៩៧ របស់លោក ញ៉ូង ស៊ាប ប្រធានគណបក្សសាធារណរដ្ឋប្រជាធិបតេយ្យខ្មែរ ។

សម្រេច

ប្រការ ១ : អនុញ្ញាតឱ្យបោះពុម្ពផ្សាយសារពត៌មាន **"ធាត្មី"** ដោយមានអ្នកស្រី **ខាវ វដ្ឋា** ជាចាងហ្វាងការផ្សាយ ។ ទីស្នាក់ការផ្ទះ លេខ៦៩ ផ្លូវសុធារស ក្រុងភ្នំពេញ ។ ក្នុងករណីមានការផ្លាស់ប្តូរចំណុចណាមួយក្នុងអត្តសញ្ញាណនៃសារពត៌មានរបស់ខ្លួនត្រូវជូនដំណឹងជាមុន ០៥ថ្ងៃមកក្រសួងពត៌មាន ដើម្បីរង់ចាំសេចក្តីសម្រេចជាថ្មី ។

ប្រការ ២ : រាល់ដំណើរការបោះពុម្ពចែកផ្សាយត្រូវគោរពតាមគោលការណ៍ ក្រមសីលធម៌អ្នកកាសែត ច្បាប់ស្តីពីរបបសារពត៌មាននិងច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។ ត្រូវប្រគល់កាសែតចំនួន០៦ច្បាប់រៀងរាល់លេខចេញផ្សាយមកតំកល់ទុកជាឯកសារនៅក្រសួងពត៌មាន ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តល្មើស នឹងសេចក្តីដូចមានចែងក្នុងប្រការទាំងឡាយខាងលើ សាមីខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៤ : អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានមណ្ឌលពត៌មាន នៃក្រសួងពត៌មាន និងចាងហ្វាងកាសែត **"ធាត្មី"** ត្រូវអនុវត្តនូវប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះមានប្រសិទ្ធភាពរយៈពេល០៣ឆ្នាំ និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ខៀវ កាញារីទ្ធ

***

៣. ទីស្តីការរដ្ឋមន្ត្រី ក្រសួងទេសចរណ៍

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ១៩៩៧

ប្រកាសលេខ ៨៥.ប្រក ស្តីពីការតែងតាំងមន្ត្រីរាជការ រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើតរចនាសម្ព័ន្ធថ្នាក់មន្ទីរសំរាប់ទេសចរណ៍ក្រុងព្រះសីហនុ
- យោងសំណើលេខ ១៨ មតចសនលស ចុះថ្ងៃទី១៨.៨.៩៧ របស់មន្ទីរទេសចរណ៍ក្រុងព្រះសីហនុ ស្តីពីសំណើសុំតែងតាំងអនុប្រធានមន្ទីរទេសចរក្រុងព្រះសីហនុ
- យោងចំណារឯកភាពលេខ ៨៤៣ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៩៧ របស់អភិបាលក្រុងព្រះសីហនុ ស្តីពីសំណើសុំតែងតាំងអនុប្រធានមន្ទីរទេសចរក្រុងព្រះសីហនុ
- យោងអនុក្រឹត្យលេខ៣៤ អនក្រ .បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងទេសចរណ៍
- យោងតាមសំណូមពរភារកិច្ចចាំបាច់នៃការងារអភិវឌ្ឍន៍វិស័យទេសចរណ៍

សំរេច

ប្រការ ១ : តែងតាំងលោក ង៉ែ ផាន បច្ចុប្បន្នជាប្រធានការិយាល័យឧស្សាហកម្ម ទេសចរណ៍ និងផែនការអភិវឌ្ឍន៍ ជាអនុប្រធានមន្ទីរទេសចរណ៍ក្រុងព្រះសីហនុ ។

ប្រការ ២ : អគ្គនាយកនៃអគ្គនាយកដ្ឋានទេសចរណ៍ នាយខុទ្ទកាល័យ ប្រធាននាយកដ្ឋានរដ្ឋបាលហិរញ្ញវត្ថុ ប្រធានមន្ទីរទេសចរណ៍ក្រុងព្រះសីហនុ និងសាមីខ្លួន ត្រូវអនុវត្តតាមប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ថោង ខុន

***

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ១៩៩៧

ប្រកាសលេខ ៨៧ . ប្រក ស្តីពីការតែងតាំងមន្ត្រីរាជការ

រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣
- យោងតាមសំណើលេខ៨៩១ កទច ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩៩៤ ស្តីពីការបង្កើត រចនាសម្ព័ន្ធថ្នាក់មន្ទីរសំរាប់ទេសចរណ៍ក្រុងព្រះសីហនុ
- យោងសំណើ លេខ០១៣ មទច.សន ចុះថ្ងៃទី១៧.០២.៩៧របស់មន្ទីរទេសចរ ក្រុងព្រះសីហនុ ស្តីសំណើសុំតែងតាំងមន្ត្រី ។
- យោងអនុក្រឹត្យលេខ៣៤ អនក្រ .បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងទេសចរណ៍
- យោងតាមសំណូមពរភារកិច្ចចាំបាច់នៃការងារអភិវឌ្ឍន៍វិស័យទេសចរណ៍

សំរេច

ប្រការ ១ : តែងតាំងលោកស្រី គួច ចន្ថា ជាអនុប្រធានការិយាល័យរដ្ឋបាល -ហិរញ្ញវត្ថុទទួលបន្ទុកប្រធានគណនេយ្យ នៃមន្ទីរទេសចរណ៍ក្រុងព្រះសីហនុ ។

ប្រការ ២ : អគ្គនាយក នៃអគ្គនាយកដ្ឋានទេសចរណ៍ នាយកខុទ្ទកាល័យ ប្រធាន នាយកដ្ឋានរដ្ឋបាល-ហិរញ្ញវត្ថុ ប្រធានមន្ទីរទេសចរណ៍ក្រុងព្រះសីហនុ និងសាមីខ្លួនត្រូវអនុវត្តតាមប្រកាស នេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ថោង ខុន

***

៤. ទីស្តីការក្រសួង ប្រៃសណីយ៍ និង ទូរគមនាគមន៍

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ១៩៩៧

ប្រកាសលេខ ១៤៥ មន , ប្រក ស្តីពីការតែងតាំងបដិភ្នាមាកៈមន្ត្រីប្រៃសណីយ៍ និងទូរគមនាគមន៍

***

រដ្ឋលេខាធិការក្រសួង ប្រៃសណីយ៍ និង ទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** រាជ្យនព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម នស-រកម ០១៩៦-២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ប្រកាសឱ្យប្រើដោយច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រម ស្តីពីសហលក្ខន្តិកមន្ត្រីរាជការស៊ីវិលលេខ ០៦/នសល/៩៤ ចុះថ្ងៃទី ២១.១០.៩៤
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី១៩ ខែកក្កដាឆ្នាំ ១៩៩៤ និងប្រកាសឱ្យប្រើនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤

- បានឃើញប្រកាសលេខ ០៨២ ប្រក-បទ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀប រចនាសម្ព័ន្ធមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ ខ្សែរយៈបណ្តោយគ្រប់ ខេត្ត-ក្រុង

- បានឃើញលិខិតលេខ ៧២ បទ ចុះថ្ងៃទី១០.៨.៩៧ របស់មន្ទីរប្រៃសណីយ៍ និងទូរគមនាគម ខេត្តស្វាយរៀង

សំរេច

ប្រការ ១ : តែងតាំងលោក **គីម ឈន** ជាបដិត្ថាហកៈរងមន្ទីរប្រៃណីយ៍ និងទូរគមនាគមន៍ ខេ ស្វាយរៀង ជំនួសលោក **សំ មីនឌុន** ដែលក្រសួងធ្វើប្រកាសផ្ទេរឱ្យទៅបំរើការងារនៅក្រ ហ៊ុនកាំមីនតែល ។

ប្រការ ២ : បដិត្ថាហកៈរងមានភារកិច្ច រួមសហការ និងទទួលខុសត្រូវលើការងារសេវាកម្ម អាជីវ ប្រៃសណីយ៍ និងទូរគមនាគមន៍ ទូទាំងខេត្ត ស្រុក ជូនមុខឱ្យក្រសួង ។

ប្រការ ៣ : ខុទ្ទកាល័យ អធិការដ្ឋាន នាយកដ៏ផែនការគណនេយ្យ-ហិរញ្ញកិច្ច មន្ទីរប្រៃណីយ៍ និងទូរគម គមន៍ខេត្តស្វាយរៀង និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្ត តាមខ្លឹមសារនៃប្រកាសនេះ ។

ប្រការ ៤ : ប្រកាសនេះមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

សូ ឃុន

***

៥. រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

សេចក្តីសំរេច

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ១៩៩៧

សេចក្តីសំរេចលេខ ៤៦១ សសរ. មស. ក្រខ ស្តីពីការបែងចែក
និស្សិតចំនួន ២៧នាក់ ដែលទើបបញ្ចប់ការសិក្សាពីបរទេស

***

រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត /០១៩៤/៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- យោងលិខិតលេខ៣១៩ សជណ.អវ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៩៥ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី

សំរេច

ប្រការ ១ : អ្នកបច្ចេកទេសថ្នាក់ឧត្ដមចំនួន ២៦នាក់ ថ្នាក់មធ្យមចំនួន ០១នាក់ ដែលបានបញ្ចប់ការសិក្សាពីបរទេស ត្រូវបានបែងចែកឱ្យទៅបំរើការងារនៅ ក្រសួងស្ថាប័នមួយចំនួន ដូចមានក្នុងតារាងឧបសម្ព័ន្ធ នៃសេចក្ដីសំរេចនេះ ។

ប្រការ ២ : ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធមានភារកិច្ចទទួលយកអ្នកបច្ចេកទេសទាំងនេះ ដើម្បីរៀបចំការងារឱ្យត្រូវតាមមុខជំនាញ និងផ្ដល់បៀវត្សជូនសាមីជន ចាប់ពីថ្ងៃដែលបានចូលបំរើការងារជាផ្លូវការ ។

ប្រការ ៣ : សេចក្ដីសំរេចនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

គ្រាត់ សុខ

***

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈរដ្ឋមន្ត្រី

ទីស្ដីការរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

តារាងឧបសម្ព័ន្ធនៃសេចក្ដីសំរេចលេខ៤៦១ សសរមស/ក្រខ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ ១៩៩៧

ស្ដីពីការបែងចែកនិស្សិត ចំនួន ២៧នាក់ ដែលបានបញ្ចប់ការសិក្សាពីបរទេស

ល.រ	នាមត្រកូល និង នាមខ្លួន	ភេទ	ថ្ងៃ.ខែ.ឆ្នាំ កំណើត	អង្គភាព ដើម	មុខជំនាញ បច្ចេកទេស	កំរិតបណ្ដុះ បណ្ដាល	បៀវត្ស	ប្រភព បណ្ដុះ បណ្ដាល

១. ក្រសួងសុខាភិបាល ចំនួន ១៣ នាក់								
១	អុម ប៊ុនឡា	ប្រុស	១៥.៧.៧០	សិស្ស	វេជ្ជសាស្ត្រ	ឧត្តម	៩០5ខី១	១
២	ទេស សូធឿន	ប	១៦.១០.៧០	-	-	-	-	១
៣	ព្រំ ប្រុស	ប	១៥.៥.៦៨	-	-	-	-	១
៤	អ៊ី ស៊ីណា	ប	០៦.៣.៧២	-	-	-	-	១
៥	មិញ កិន្នារ៉ា	ប	៦.១១.៧២	-	-	-	-	១
៦	រាជ រតនា	ប	០៣.៩.៦៩	-	-	-	-	១
៧	ស៊ាង សារឿន	ប	៣.១១.៦៩	-	-	-	-	១
៨	ទុយ អបរិទ្ធ	ប	២៥.៨.៦៨	ប.ឧសក	-	-	ខ១	១
៩	កៅ លុយប៉ូ	ប	១០.១.៧១	សិស្ស	-	-	៩០5ខី១	១
១០	ង៉ែត វ៉ាន់ធូក	ប	០៥.៥.៧២	-	-	-	-	១
១១	លី ហ៊ួសូ	ប	០៥.៥.៦៨	-	-	-	-	១
១២	អ៊ូ សុខហាក់	ប	០៨.៤.៦៧	-	-	-	-	១
១៣	ល័ស ពិនិត្យ	ប	០៥.១០.៧០	-	-	-	-	១
២. ក្រសួងសាធារណការ និងដឹកជញ្ជូន ចំនួន ០៧ នាក់								
១៤	អ៊ី ប៊ុនថន	ប	១៥.១.៦៨	សិស្ស	សំណង់ស៊ីវិល ឧ សក	ឧត្តម	៩០5ខី១	១
១៥	ខេង ធិរៈមុនី	ប	០៣.៤.៧០	-	-	-	-	១
១៦	ឃ្លាំង វុទ្ធិន	ប	០៧.២.៧៣	-	-	-	-	១
១៧	គង់ សុភា	ប	១.១០.៧៣	-	-	-	-	១
១៨	ស៊ាន ស៊ីដារ៉ូ	ប	២០.៥.៧៣	-	សំណង់ស្ពានថ្នល់	-	90%ខI	១
១៩	សុខ វ៉ាន្ណា	ប	១២.៥.៦០	ប.សំណង់	សំណង់	-	90%ខI	៣
២០	ប៉េង ពុធដាឡឹង	ប	០៥.៧.៧២	សិស្ស	ជួសជុលម៉ាស៊ីនរថយន្ត	មធ្យម	90%ខII	២

៣- ក្រសួងមហាផ្ទៃ ចំនួន ០២ នាក់								
២១	បែន វឌ្ឍនា	ប	១០.៣.៧២	សិស្ស	សំណង់ស៊ីវិល ឧសក	ឧត្តម	៩០៥ខ៊ី១	១
២២	យឿង កុសល	ប	២០.៦.៦៦	បុ យុវជន	កុំព្យូទ័រ	-	ខ៊ី១	១
៤- ក្រសួងពាណិជ្ជកម្ម ចំនួន ០១ នាក់								
២៣	កោះ និច្ច	ប	២៦.០១.៧៤	សិស្ស	កុំព្យូទ័រ	ឧត្តម	៩០៥ខ៊ី១	១
៥- ក្រសួង ទេសចរណ៍ ចំនួន ០១ នាក់								
២៤	គង់ សុធារក្ស	ប	១៨.៨.៧២	សិស្ស	កុំព្យូទ័រ	ឧត្តម	៩០៥ខ៊ី១	១
៦- ក្រសួង ឧស្សាហកម្មរ៉ែ និង ថាមពល ចំនួន ០១ នាក់								
២៥	សុខ គីមជឿន	ប	០៨.៣.៦៨	សិស្ស	បច្ចេកទេសគីមី	ឧត្តម	៩០៥ខ៊ី១	១
៧- ក្រសួង ប្រៃសណីយ៍ និង ទូរគមនាគមន៍ ចំនួន ០១ នាក់								
២៦	តុល ញ៉ក់	ប	០១.៣.៧៣	សិស្ស	អេឡិចត្រូនិច-ទគម	ឧត្តម	៩០៥ខ៊ី១	១
៨- ក្រសួង កសិកម្មរុក្ខាប្រមាញ់ និង នេសាទ ចំនួន ០១ នាក់								
២៧	នូ ណារុទ្ធ	ប	០៥.០២.៧២	សិស្ស	ចញ្ចឹមសត្វ	ឧត្តម	៩០៥ខ៊ី១	១

សេចក្ដីបញ្ជាក់

១-ប្រទេសវៀតណាម

២-ប្រទេសសូវៀត

៣-ប្រទេសអាឡឺម៉ង់

បានបញ្ឈប់បញ្ជីនេះត្រឹមចំនួន២៧ "ម្ភៃប្រាំពីរ" នាក់ប៉ុណ្ណោះ ។

រាជធានីភ្នំពេញ.ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ១៩៩៧

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

គ្រាក់ សុខ

★★★

៦. ទីស្តីការក្រសួង ធម្មការ និង សាសនា

សេចក្តីសំរេច

រាជធានីភ្នំពេញ ថ្ងៃ... ខែ សីហា ឆ្នាំ ១៩៩៧

សេចក្តីសំរេចលេខ ១៩៦ កធស

***

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនាដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម លេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦
- បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជាលេខ ០៦ នស១៩៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩២ ស្តីពីការរៀបចំនិងប្រព្រឹត្តិទៅនៃក្រសួងធម្មការ និងសាសនា
- បានឃើញពាក្យសុំបើកសាខាស្នាក់ការ ថ្វាយបង្គំព្រះគ្រីស្តនិកាយប្រូតេស្តង់ "ក្រុមជំនុំគ្រប់ជនជាតិទីក្រុងភ្នំពេញ" របស់លោក ពេជ ផាន ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៩៧
- បានឃើញចំណារបញ្ជូន របស់លោកនាយកមន្ទីរធម្មការ និងសាសនា រាជធានីភ្នំពេញ លេខ ១៣៣ / ៩៧ ស.ធ.ស.ភព ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៩៧

សំរេច

ប្រការ ១ : អនុញ្ញាតឱ្យបើកសាខាស្នាក់ការបណ្តោះអាសន្នសំរាប់ថ្វាយបង្គំព្រះគ្រីស្តនិកាយប្រូតេស្តង់ នៃព្រះវិហារឈ្មោះហៅថា **"ក្រុមជំនុំគ្រប់ជនជាតិទីក្រុងភ្នំពេញ"** មួយកន្លែងដែលមានទីតាំងស្ថិតនៅ ផ្ទះលេខ២៤២ ផ្លូវលេខ១៣២ សង្កាត់ទឹកល្អក់ទី១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ។

ប្រការ ២ : សាខាស្នាក់ការថ្វាយបង្គំព្រះគ្រីស្ត និកាយប្រូតេស្តង់ នៃព្រះវិហារ "ក្រុមជំនុំគ្រប់ជនជាតិទីក្រុងភ្នំពេញ" ត្រូវអនុញ្ញាតឱ្យប្រើប្រាស់និងផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗ របស់លទ្ធិសាសនាគ្រីស្តដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ ៣ : បរិស័ទទាំងអស់របស់ព្រះវិហារឈ្មោះ **"ក្រុមជំនុំគ្រប់ជនជាតិទីក្រុងភ្នំពេញ"** ត្រូវគោរពនិង អនុវត្តឱ្យបានត្រឹមត្រូវម៉ឺងម៉ាត់តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងរាល់បទបញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការ និងសាសនា ។ អ្នកដឹកនាំ នៃសាខាស្នាក់ការខាងលើនេះ ត្រូវមានសាមគ្គីភាព និងទំនាក់ទំនងឱ្យបានល្អជាមួយស្ថាប័នពាក់ព័ន្ធ សន្យាជាដាច់ខាតមិនធ្វើឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពខាងជំនឿសាសនា និងសណ្តាប់ធ្នាប់ របៀបរៀបរយសង្គម ។

ប្រការ ៤ : រាល់ការអនុវត្តទាំងឡាយណា ដែលផ្ទុយពីសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : នាយកដ្ឋានសាសនា-មន្ទីរធម្មការ និងសាសនា រាជធានីភ្នំពេញ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ដែលមានភារកិច្ចពាក់ព័ន្ធ ត្រូវសហការអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ។

ប្រការ ៦ : សេចក្តីសំរេចនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ឃឿន វណ្ណារ័ត្ន

★★★

បោះពុម្ពនៅរោងពុម្ព ទីស្ដីការគណៈរដ្ឋមន្ត្រី
លើកទី១ ចំនួន ៨០០ ច្បាប់

តម្លៃ ២៧៥០ រៀល